# សន្និសីទអន្តរជាតិស្តីពីអាជីវកម្មរ៉ែ

# “ឱកាសសម្រាប់កម្ពុជា”

### ភ្នំពេញ ថ្ងៃទី ២៦-២៧ ខែ ឧសភា ឆ្នាំ ២០១០

## ដំណើរការនៃកិច្ចការពារបរិស្ថាន — ភាពចាំបាច់ឱ្យមានការធ្វើអាជីវកម្មរ៉ែ តាមបែបទំនើប

## ទស្សនៈវិស័យពីអង្គការសង្គមស៊ីវិលកម្ពុជា

ដោយ **Jason D. Jones,** ទីប្រឹក្សា

បណ្តាញនៃផលប៉ះពាល់ខាងសង្គម និងបរិស្ថានពីឧស្សាហកម្មនិស្សារណកម្ម **(EISEI)**

# ដំណើរការការពារបរិស្ថាន – ការប្រឈមនៅកម្ពុជា

ការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវនូវបរិស្ថានសង្គម វប្បធម៌ និងធម្មជាតិ របស់កម្ពុជា ទាមទារឱ្យជំនះបាននូវការប្រឈមជាច្រើន នៅកម្រិតសហគមន៍ ខេត្ត ជាតិ និងអន្តរជាតិ។

ក្នុងចំណោមការប្រឈមទាំងនេះ ប្រការដែលទាក់ទងនឹងគោលនយោបាយ អាចតំណាងឱ្យឱកាសដ៏ប្រសើរ និងឆាប់រហ័សបំផុត ក្នុងការធ្វើឱ្យមានការប្រែប្រួលវិជ្ជមាន។ ជាពិសេស ការយកចិត្តទុកដាក់របស់យើង ត្រូវផ្តោតលើកិច្ចការទាំងប្រាំខាងក្រោមនេះ ៖

1. កង្វះផែនការប្រើប្រាស់ដីនៅថ្នាក់ជាតិដែលមានលក្ខណៈទូលំទូលាយ និងដែលអាចអនុវត្តបានជាទូទៅ
2. ភាពត្រួតគ្នានៃផលប្រយោជន៍ ដែលប្រកួតប្រជែងគ្នាក្នុងការទាមទារធនធានដែលមានក្នុងកម្រិតកំណត់
3. កិច្ចការពង្រឹងការអនុវត្តបទប្បញ្ញត្តិបរិស្ថាននានាដែលមានស្រាប់ នៅមិនទាន់គ្រប់គ្រាន់នៅឡើយ
4. ភាពទន់ខ្សោយនៃបទប្បញ្ញត្តិខាងបរិស្ថានដែលមានស្រាប់
5. ការពាក់ព័ន្ធរបស់សហគមន៍នៅក្នុងដំណើរការកសាងផែនការបរិស្ថាន

# ការវិភាគ SWOT – ដំណើរការការពារបរិស្ថាននៅកម្ពុជា

## ភាពខ្លាំង

1. មានមូលដ្ឋានច្បាប់រឹងមាំ
2. ចំណាប់អារម្មណ៍លើការកសាងសមត្ថភាពរបស់សហគមន៍ រដ្ឋាភិបាល និងវិស័យឯកជន
3. ស្ថានភាពបរិស្ថានមានគុណភាពខ្ពស់ ដែលលើកទឹកចិត្តឱ្យមានការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ

## ភាពទន់ខ្សោយ

1. ច្បាប់ដែលមានស្រាប់ មិនត្រូវបានយកមកអនុវត្ត
2. សមត្ថភាពដែលមានស្រាប់នៅទាប ក្នុងគ្រប់វិស័យ
3. អារម្មណ៍អវិជ្ជមាន ដែលចាត់ទុកថា ការកសាងផែនការបរិស្ថានជាឧបសគ្គចំពោះការអភិវឌ្ឍសេដ្ឋកិច្ចដោយជោគជ័យ

## ឱកាស

1. ការពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិបរិស្ថាន
2. ធ្វើការសហការគ្នាដើម្បីកសាងសមត្ថភាពនៅគ្រប់លំដាប់ថ្នាក់
3. ធ្វើឱ្យអ្នកពាក់ព័ន្ធទាំងអស់ ចូលរួមក្នុងការដើរតួនាទីជាវិជ្ជមាន នៅក្នុងការថែរក្សាគុណភាពបរិស្ថានរបស់កម្ពុជា

## ការគំរាមកំហែង

1. មិនអាចឈានដល់ការឯកភាពគ្នា លើរបៀបពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិ
2. កង្វះទំនុកចិត្តគ្នារវាងអ្នកពាក់ព័ន្ធនានា
3. ការលំបាកនៅក្នុងការសម្របសម្រួលសកម្មភាពរបស់អ្នកពាក់ព័ន្ធ ដើម្បីសម្រេចគោលដៅរួមនៃកិច្ចការពារបរិស្ថានឱ្យប្រសើរជាងមុន

# ការធានាឱ្យមានកិច្ចការពារបរិស្ថានបានល្អនៅកម្ពុជា –

# តើធ្វើដូចម្តេច?

ប្រទេសទីម័រខាងកើត ផ្តល់ជាគំរូល្អមួយសម្រាប់គ្រប់គ្រងផលប៉ះពាល់ខាងសង្គម និងបរិស្ថាន ដែលទាក់ទងជាមួយការពង្រីកឧស្សាហកម្មនិស្សារណកម្ម ។ ធាតុសំខាន់ៗ រួមមាន :

1. ធ្វើឱ្យសហគមន៍ចូលរួមនៅក្នុងដំណើរការកសាងផែនការយុទ្ធសាស្រ្ត
2. ចែករំលែកផែនការយុទ្ធសាស្រ្តជាមួយដៃគូអភិវឌ្ឍន៍

គោលការណ៍នេះទាមទារឱ្យមានការអប់រំ ក្នុងស្រទាប់មហាជន ដើម្បីកសាងសមត្ថភាពសហគមន៍ សម្រាប់ចូលរួមនៅក្នុងដំណើរការកសាងផែនការបរិស្ថាន

ដូចគ្នានេះដែរ បណ្តាញ EISEI ប្រឹងប្រែងដើម្បីពង្រឹងសិទ្ធិអំណាចរបស់សហគមន៍ ឱ្យដើរតួសកម្មនៅក្នុងការធានាឱ្យមានដំណើរការជាវិជ្ជមានសម្រាប់ការពារបរិស្ថាននៅកម្ពុជា

- បណ្ដាញ **EISEI** ផ្ដោតការយកចិត្តទុកដាក់លើ ការធ្វើទំនាក់ទំនង ការចែករម្លែកចំណេះដឹង និងការសម្រួលឱ្យមានការពិភាក្សា រវាងសហគមន៍ អង្គការសហគមន៍ ក្រសួងនានានៃរដ្ឋាភិបាល និងក្រុមហ៊ុនរ៉ែ លើបញ្ហាឧស្សាហកម្មនិស្សារណកម្ម។

- សមាជិកនានា សព្វថ្ងៃនេះ រួមមាន បុគ្គល និងអង្គការសហគមន៍ នៅទូទាំងប្រទេសកម្ពុជា។ គណៈកម្មាធិការដឹកនាំ រួមមាន **DPA, EWMI, ICSO, VOD, YRDP, SCW, MVI** និងអង្គការដទៃទៀត។ សព្វថ្ងៃនេះ ការកសាងផែនការយុទ្ធសាស្ត្រ បានផ្ដោតលើការអប់រំ ការវិភាគ និងការតស៊ូមតិ ។

- កិច្ចប្រឹងប្រែងទៅអនាគត រួមមាន កសាងសមត្ថភាពខាងការអប់រំ តស៊ូមតិ និងវិភាគ ដើម្បីពង្រឹងសិទ្ធិអំណាចរបស់ អ្នកពាក់ព័ន្ធនានា ដើម្បីធ្វើការដោះស្រាយប្រកបដោយការប្រមើកទុកជាមុន និងកាត់បន្ថយផលប៉ះពាល់សង្គម និងបរិស្ថាន ដែលកើតចេញពីឧស្សាហកម្មនិស្សារណកម្មនៅកម្ពុជា។







# ធ្វើបែបណា?


សហគមន៍ជនរង
គ្រោះ/សហគមន៍
N Os
បណ្តាញ
EISEI
ក្រសួងនានានៃ
រដ្ឋាភិបាល
ក្រុមហ៊ុនឧស្សាហ
កម្ម និស្សារណកម្ម

ផែនការផ្សព្វផ្សាយនិងអប់រំរបស់ **EISEI** ផ្តោតលើអ្នកពាក់ព័ន្ធខុសៗគ្នា នៅច្រើន

លំដាប់ថ្នាក់ ដូចជា :

- ថ្នាក់សហគមន៍ / មូលដ្ឋាន និងថ្នាក់ខេត្ត
- ថ្នាក់រដ្ឋាភិបាល /ជាតិ
- ឧស្សាហកម្ម / អន្តរជាតិ



ការតស៊ូមតិដើម្បីបង្កើនការយល់ដឹងអំពីបញ្ហាជាច្រើន ដែលទាក់ទងនឹងឧស្សាហកម្មនិស្សារណកម្ម គឺជាសកម្មភាពយ៉ាងសំខាន់ ដែលជាស្នូលនៃជោគជ័យរបស់បណ្ដាញ **EISEI** ។ អាស្រ័យហេតុនេះ **EISEI** ពុះពារដើម្បីសម្របសម្រួលកិច្ចប្រឹងប្រែងនានាលើការតស៊ូមតិ ដើម្បីធ្វើឱ្យអ្នកពាក់ព័ន្ធនៅលំដាប់ថ្នាក់នានាដូចខាងក្រោមនេះ បានចូលរួម :

- ថ្នាក់សហគមន៍ / មូលដ្ឋាន និងថ្នាក់ខេត្ត
- ថ្នាក់រដ្ឋាភិបាល /ជាតិ
- ឧស្សាហកម្ម / អន្តរជាតិ



ដើម្បីបង្កើតឱ្យមានវេទិកាដែលគ្មានភាពលំអៀង សម្រាប់ការពិភាក្សា និងដំណោះស្រាយចំពោះបញ្ហា EI, EISEI បានត្រៀមខ្លួនដើម្បីធ្វើការវិភាគ ឬសម្របសម្រួលឱ្យមានការវិភាគដោយឯករាជ្យ នូវបញ្ហានានា ដែលទាក់ទងនឹងសកម្មភាព EI ដែលបានរាយការណ៍ដោយសមាជិកបណ្តាញនេះ។ ក្នុងន័យនេះ EISEI មានសមត្ថភាពដើម្បីអនុវត្ត ឬ ចាត់ចែងសកម្មភាពដូចខាងក្រោមនេះ ដើម្បីផ្តល់នូវការវាយតម្លៃដោយឯករាជ្យ និងដែលចាំបាច់សម្រាប់ចាប់ផ្តើមការពិភាក្សា ។

- ការប្រមូលព័ត៏មានអំពីប្រវត្តិដើម និងទិន្នន័យគោល
- ធ្វើការជាមួយសហគមន៍ជនរងគ្រោះ ដើម្បីរៀបចំការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់សង្គម និងបរិស្ថាន (ISEIA);
- លើកអនុសាសន៍សម្រាប់ការវាយតម្លៃហេតុបះពាល់បរិស្ថាននៅពេលក្រោយ ការវាយតម្លៃហេតុប៉ះបាល់បរិស្ថាន (EIA) ឬ ការវាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថាន (SEIA);
- ប្រសិនបើចាំបាច់ អាចដើរតួជាអង្គភាពកណ្តាលមួយ សម្រាប់សម្របសម្រួលការចូលរួមរបស់សហគមន៍ និងរដ្ឋាភិបាល នៅក្នុងដំណើរការ EIA/SEIA (ដូចជា ការសម្របសម្រួលដំណើរការផ្តល់យោបល់ ការប្រជុំរបស់សហគមន៍ ។ល។)
- ការសម្របសម្រួល ឬ ធ្វើការផ្ទៀងផ្ទាត់ដោយឯករាជ្យ ដែលទាមទារឱ្យមានការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ ឬវិធានការតាមដាន។

សូមអរគុណ!

យើងរំពឹងថានឹងអាចធ្វើការជាមួយគ្នានៅអនាគត!